ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
NGO EDUCATION PARTNERSHIP

# ព្រឹត្តិបត្រ NEP

**មេសា ២០០៨ - ចេញផ្សាយលេខ ៧**

NEP ផ្តល់នូវយន្តការមួយ ដើម្បីលើកកំពស់កិច្ចចរចារក្នុងចំណោមអង្គការជាសមាជិករបស់ខ្លួន និងជាមួយរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការលើកកំពស់គុណភាពអប់រំសំរាប់ទាំងអស់គ្នាក្នុងស្មារតីសហប្រតិបត្តិការ ។

## ព័ត៌មានថ្មីៗពីលេខាធិការដ្ឋាន NEP

### សារពីនាយកប្រតិបត្តិ

យើងទាំងអស់គ្នាមានសេចក្តីរីករាយក្រៃលែង ចំពោះវត្តមានអង្គការសមាជិក និង ភ្ញៀវកិត្តិយសនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់យើងកាលពីខែមុន ។ វាជាឱកាសដ៏ល្អសំរាប់យើងក្នុងការជួបប្រជុំគ្នាដើម្បីពិភាក្សាអំពីបញ្ហា និងសកម្មភាពភាពមួយចំនួន ដែលនឹងជួយធ្វើឱ្យសំលេងនៃអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការក្នុងវិស័យអប់រំរឹតតែមានសន្ទុះខ្លាំងឡើង ។

យើងប្តេជ្ញា ឱ្យមានទំនាក់ទំនងល្អជាមួយអង្គការសមាជិកនៅឆ្នាំនេះ ប៉ុន្តែសូមឱ្យមានការចូលរួមឱ្យបានសកម្មពីអង្គការសមាជិកដើម្បីសំរេចបានគោលដៅទាំងនេះ ។ ព័ត៌មានបានពីអង្គការសមាជិក ត្រូវបានដាក់បញ្ចូលនៅក្នុងគេហទំព័រថ្មីរបស់យើង គឺ www.nepcambodia.org និងនៅក្នុងព្រឹត្តិបត្រនេះ ។ សូមជួយចែករំលែកព័ត៌មានពីអង្គការរបស់អ្នក ដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ផ្សេងៗ ក៏ដូចជាការស្រាវជ្រាវ និង របាយការណ៍ថ្មីៗដែលអ្នកគិតថាមានសារប្រយោជន៍ចំពោះសមាជិក NEP ។

យើងខ្ញុំទន្ទឹងរងចាំធ្វើការងារជាមួយអ្នកឱ្យបានជិតស្និទ្ធថែមទៀតនៅឆ្នាំខាងមុខ ។

អ៊ូ វិយូរ៉ែន

### កិច្ចប្រជុំប្រចាំឆ្នាំ ២០០៨

នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ ថ្ងៃទី ២៤ ខែ មីនាកន្លងទៅនេះ លោក ចាន់ សូលីន ប្រធានក្រុមប្រឹក្សាភិបាល NEPដែលចប់អាណត្តិ បានធ្វើសេចក្តីថ្លែងអំណរគុណដល់សមាជិកក្រុមប្រឹក្សាភិបាល និង បុគ្គលិកទាំងអស់ចំពោះការគាំទ្ររបស់គេក្នុងអំឡុងពេលបំរើការងារឱ្យ NEP ។ គាត់បង្ហាញអំពីជំនឿទុកចិត្តយ៉ាងខ្លាំងចំពោះអនាគតរបស់ NEP ។

### សង្ខេបព្រឹត្តិការណ៍ឆ្នាំ ២០០៧ និង ២០០៨

នាយកប្រតិបត្តិរបស់ NEP លោក អ៊ូ វិយូរ៉ែនបានធ្វើបទបង្ហាញសកម្មភាពសំខាន់ៗរបស់ NEP ក្នុងឆ្នាំ ២០០៧ ។ អ្នកស្រី អាង សូផា ដែលជាអ្នកស្រាវជ្រាវរបស់ NEP បានជួយជួយចែករំលែកធ្វើបទបង្ហាញ នូវចំនុចសំខាន់ៗមួយចំនួននៃរបាយការណ៍អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារក្នុងវិស័យអប់រំនៅឆ្នាំ ២០០៧ ដោយផ្តោតទៅលើសកម្មភាពរបស់អង្គការទាំងនោះនៅក្នុងគោលដៅទាំង ៦នៃការអប់រំសំរាប់ទាំងអស់គ្នា ។ សំរាប់ច្បាប់ចតចំលងរបាយការណ៍នេះ សូមធ្វើការទំនាក់ទំនងទៅកាន់អាសយដ្ឋាន : sopha@nepcambodia.org



*ប្រធានក្រុមប្រឹក្សាភិបាលថ្មីរបស់NEP លោក គឹម តារា (ឆ្វេង) និង អ្នកចូលរួមនៅក្នុងការពិភាក្សាជាក្រុមអំពីការងារអាទិភាព NEP នៅឯកិច្ចប្រជុំប្រចាំឆ្នាំ*

លោក វន សំភាស់ ដែលជាសមាជិកក្រុមប្រឹក្សាភិបាល NEP និង ជាប្រធានគណកម្មាធិការដឹកនាំយុទ្ធនាការជាសកលសំរាប់ការអប់រំ (GCE) បានធ្វើបទបង្ហាញដោយសង្ខេបអំពីយុទ្ធនាការជាសកលសំរាប់ការអប់រំ និង ផែនការមួយចំនួនដើម្បីរៀបចំសប្តាហ៏សកម្មភាពជាសកល ។ ចំពោះព័តិមានបន្ថែម អំពីសប្តាហ៏សកម្មភាពជាសកលសំរាប់ការអប់រំដែលរៀបចំធ្វើនៅឆ្នាំនេះពីថ្ងៃទី ២១ ដល់ ២៨ ខែ មេសា ឆ្នាំ ២០០៨ សូមធ្វើការទំនាក់ទំនងតាមរយៈអាសយដ្ឋាន : theavy@nepcambodia.org

នាយកប្រតិបត្តិ NEP លោក អ៊ូ វិយូរ៉ែនក៏បានធ្វើបទបង្ហាញអំពីព្រឹត្តិការណ៏សង្ខេបនៅឆ្នាំ ២០០៨ ផងដែរ :

លោក អ៊ូ វិយូរ៉ែនបានលើកឡើងថា NEP បានចូលរួមក្នុងកិច្ចពិភាក្សារៀបចំផែនការ ទៅលើការវាយតំលៃពាក់កណ្តាលអាណត្តិរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និង កម្មវិធីគាំទ្រវិស័យអប់រំ ជាមួយនាយកដ្ឋានផែនការការរបស់ក្រសួងអប់រំ យុវជន និង កីឡា រួមជាមួយដៃគូអភិវឌ្ឍន៏ធំៗមួយចំនួនទៀត ។ NEP បានចូលរួមផ្តល់ជាមតិយោបល់ស្តីអំពីដំណើរការរីកចំរើននៅក្នុងវិស័យគោលដៅចរន្តទាំង ៦ និង ធ្វើបទបង្ហាញនៅក្នុងវេទិកាវាយតំលៃពាក់កណ្តាលអាណត្តិដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និង កីឡា នៅថ្ងៃទី ៣១ ខែ មីនា និង ថ្ងៃទី ១ ទី ២ ខែមេសា ។

នៅក្នុងវេទិកានោះមានមន្ត្រីជាច្រើនរូបមកពីក្រសួង និង មានបុគ្គលិកប្រហែល ៥០០ នាក់ មកពីទីក្រុងភ្នំពេញ និង ពីតាមខេត្ត ដៃគូអភិវឌ្ឍន៍ និង សមាជិក NEP បានធ្វើការពិភាក្សាទៅលើឯកសាររួមគ្នាសំខាន់ៗដើម្បីធ្វើការវាយតំលៃពាក់កណ្តាលអាណត្តិរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និង កម្មវិធីគាំទ្រវិស័យអប់រំ ។ លោក អ៊ូ វិយូរ៉ែន ធ្វើសេចក្តីថ្លែងការណ៏សង្ខេបក្នុងនាមអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារក្នុងវិស័យអប់រំ ដោយបានសង្កត់ធ្ងន់ថា សមាជិក NEP ចង់ធ្វើការសហការជាមួយរដ្ឋាភិបាល ដើម្បីគាំទ្រឱ្យមានការរីកចំរើន ។

ការសិក្សាស្រាវជ្រាវឆ្នាំ ២០០៨ : របាយការណ៏នៃអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារក្នុងវិស័យអប់រំឆ្នាំ ២០០៨ នឹងត្រូវបានរៀបចំរួចរាល់ឱ្យទាន់សន្និបាតអប់រំនៅដើមឆ្នាំ ២០០៩ ។ ចំពោះការផ្តួចផ្តើមសិក្សាស្រាវជ្រាវមួយទៀត អ្នកស្រី Sarah Jago ជាទីប្រឹក្សាថ្មីរបស់ VSO កំពុងធ្វើការងារដើម្បីបញ្ចប់របាយការណ៏ស្តីអំពីគុណតំលៃរបស់គ្រូបង្រៀន ។

*ការងារអាទិភាពសំរាប់ឆ្នាំ ២០០៨ :* សមាជិក NEP ធ្វើការពិភាក្សាការងារអាទិភាពចំនួន ៤ ដែលបានលើកឡើងនៅក្នុងបទបង្ហាញអំពីការងារសំខាន់សំរាប់ឆ្នាំ ២០០៨ ។

- ការទំនាក់ទំនងជាមួយសមាជិក និង ការកសាងសមត្ថភាព
- ការកែទំរង់គោលនយោបាយ: ការវាយតំលៃពាក់កណ្តាលអាណត្តិទៅលើផែនការយុទ្ធសាស្ត្រវិស័យអប់រំ និង កម្មវិធីគាំទ្រវិស័យអប់រំ
- ការសិក្សាស្រាវជ្រាវ
- ប្រសិទ្ធភាពការងាររបស់ NEP

សមាជិកទាំងអស់ត្រូវបានតំរូវឱ្យឆ្លើយសំនួរចំនួនពីរដែលជាផ្នែកមួយនៃកិច្ចពិភាក្សាជាក្រុម :

1. តើអ្នកចង់ឃើញ NEP ធ្វើអ្វីខ្លះនៅតាមវិស័យអាទិភាព

និមួយៗនៅឆ្នាំ ២០០៩ នេះ?

2. តើអង្គការរបស់អ្នកអាចជួយរួមចំណែក យ៉ាងដូចម្តេច ក្នុងការធ្វើឱ្យសំរេចបានការងារអាទិភាពទាំងនេះ?

*ព័ត៌មានសង្ខេបចំពោះកិច្ចពិភាក្សានោះ មាននៅក្នុងកំណត់ត្រារបស់កិច្ចប្រជុំប្រចាំឆ្នាំ ។*

## ការជ្រើសរើសក្រុមប្រឹក្សាភិបាល NEP

លោក កាន់ កាល់មកពីអង្គការន័រវេស៍សង្គ្រោះកុមារ លោក កេត ចាន់តូ មកពីអង្គការទស្សនៈពិភពលោក និង លោក វ៉ន សំភាស់ មកពីក្រុមប្រឹក្សាសកម្មភាពជនពិការ នៅបន្តការងារជាក្រុមប្រឹក្សាភិបាលរបស់ NEP សំរាប់ឆ្នាំទី ២ នៃអាណត្តិ ២ឆ្នាំរបស់ខ្លួន ។

អង្គការសមាជិកត្រូវឱ្យធ្វើការជ្រើសរើស ក្រុមប្រឹក្សាភិបាលសំរាប់ឆ្នាំ ២០០៨។ លោក គីម តារា មកពីអង្គការអប់រំពិភពលោក និង លោក Andy Hill មកពីអង្គការ SCC ត្រូវបានជ្រើសរើស ជាសមាជិកក្រុមប្រឹក្សាភិបាលថ្មីនៃក្រុមប្រឹក្សាភិបាលដែលមានសមាជិក ៥រូបរបស់ NEP ។

លោក អ៊ូ វិយូរ៉ែន បានថ្លែងអំណរគុណដល់ប្រធានក្រុមប្រឹក្សាភិបាលដែលចប់អាណត្តិគឺ លោក ចាន់ សូលីន ចំពោះការងាររបស់គាត់រយៈពេល ៣ឆ្នាំ និង ថ្លែងអំណរគុណផងដែរចំពោះលោកស្រី Alice Castillejo ចំពោះការចូលរួមយ៉ាងសកម្មរបស់គាត់ជាសមាជិកក្រុមប្រឹក្សាភិបាល ។

ដើម្បីទទួលបានច្បាប់ថតចំលង បទបង្ហាញដែលធ្វើនៅក្នុងកិច្ចប្រចាំឆ្នាំ និង ជីវប្រវត្តិរបស់ក្រុមប្រឹក្សាភិបាលថ្មី ។ សូមចូលទៅគេសហទំព័រ តាមរយៈអាសយដ្ឋាន : www.nepcambodia.org

## ជួបជាមួយបុគ្គលិក NEP !

សូមថ្លែងអំណរគុណ ចំពោះការជួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីអង្គការ UNICEF និង ម្ចាស់មូលនិធិសំខាន់មួយទៀត គឺ Misereor ព្រមទាំងការជួយឧបត្ថម្ភផ្នែកបច្ចេកទេសតាមរយៈ ទីប្រឹក្សាស្ម័គ្រចិត្តជាច្រើនរូបមកពីអង្គការ VSO ។ យើងកំពុងបោះជំហានទៅមុខ ។

NEP មានក្រុមការងាររឹងមាំ ដែលកំពុងខិតខំបំពេញការងារ ដោយផ្តោតសំខាន់ទៅលើការឱ្យតំលៃដល់សមាជិករបស់ខ្លួន ពង្រឹងទំនាក់ទំនងរវាងរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលធ្វើការងារលើវិស័យអប់រំ និង ជំរុញឱ្យមានសំលេងកាន់តែខ្លាំងឡើងនៅក្នុងវិស័យដែលយើងកំពុងតែបំពេញការងារ ស្តីអំពីបញ្ហាមួយចំនួននៅក្នុងវិស័យអប់រំដែលតំរូវឱ្យមានដំណោះស្រាយសមស្រប ។

លោក អ៊ូ វិយូរ៉ែន ចូលបំរើការងារជានាយកប្រតិបត្តិនៅ NEP នាចុងខែ មករា ឆ្នាំ ២០០៨ ។ គាត់មានបទពិសោធន៍យ៉ាងទូលំទូលាយផ្នែកត្រួតពិនិត្យ និង វាយតំលៃលើកំណែទំរង់គោលនយោបាយ និង ការអនុវត្តយុទ្ធសាស្ត្រសកម្មភាពស្តីអំពីអាទិភាពការងារអភិវឌ្ឍន៍ដែលជាប់ពាក់ព័ន្ធនឹងរដ្ឋាភិបាល ម្ចាស់ជំនួយ និង អង្គការមិនមែនរដ្ឋាភិបាល ។ គាត់ធ្លាប់បម្រើការងារ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) អស់រយៈពេល ៤ឆ្នាំ ដែលការងារគាត់ភាគច្រើនធ្វើជាមួយនាយកដ្ឋានសំរបសំរួលជំនួយទ្វេភាគីជាមួយ សហគមអឺរ៉ុប និង អាមេរិកខាងជើង ។

កញ្ញា លេង ធាវី ចូលបំរើការងារនៅ NEP ចាប់ពី ខែ កក្កដា ឆ្នាំ ២០០៧ ហើយគាត់ទទួលខុសត្រូវលើផ្នែកអប់រំ និង ពង្រឹងសមត្ថភាព ។ ធាវី បានបំរើការងារជាច្រើនផ្នែកនៅ NEP ពីព្រោះពេលគាត់មកបំរើការងារ ពេលនោះមានតែនាយកប្រតិបត្តិ បុគ្គលិកម្នាក់ និង បុគ្គលិកស្ម័គ្រចិត្តមកពី VSO ម្នាក់ប៉ុណ្ណោះ ។ បើគិតទៅលើចំនួនបុគ្គលិកកើនឡើង និង ការប្តេជ្ញាចិត្តរបស់យើងក្នុងការពង្រឹងទំនាក់ទំនង និង កសាងសមត្ថភាពជាមួយសមាជិក អ្នកនឹងបានឃើញបន្ថែមទៀតពី ធាវីនៅឆ្នាំខាងមុខ ។

អ៊ីមែល: theavy@nepcambodia.org



*បុគ្គលិក NEP នៅឯកិច្ចប្រជុំប្រចាំឆ្នាំ*

អ្នកស្រី **អាង សូផា** ដែលជាមន្ត្រីស្រាវជ្រាវ បានចូលបំរើការងារនៅ NEP នៅចុងខែ វិច្ឆិកា ឆ្នាំ ២០០៧ ហើយទទួលខុសត្រូវលើការសរសេររបាយការណ៍នៃអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើវិស័យអប់រំ ឆ្នាំ ២០០៧ ដែលរបាយការណ៍នោះមានការយឺតយ៉ាវក្នុងការសរសេរបញ្ចប់ ដោយសារការផ្លាស់ប្តូរការគ្រប់គ្រង និង បុគ្គលិកមានកំណត់ ។ សូផានឹងមានឱកាសក្នុងការរៀបចំ ស្រាវជ្រាវ និង សរសេររបាយការណ៍កាន់តែទូលំទូលាយថែមទៀតនៅឆ្នាំនេះ ។ ឥលូវ គាត់កំពុងរៀបចំវិធីសាស្ត្រស្រាវជ្រាវ សំរាប់ការសិក្សាស្រាវជ្រាវមួយស្តីអំពីការអប់រំថ្នាក់មត្តេយ្យ និង ឥទ្ធិពលរបស់វាទៅលើការចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សាដែលយើងគ្រោងនឹងបោះពុម្ពនៅខែ សីហា ឆ្នាំ ២០០៨ ។

អ៊ីមែល: sopha@nepcambodia.org

លោក **កែវ សុខា** ជាមន្ត្រីរដ្ឋបាល និង ហិរញ្ញវត្ថុ ។ គាត់ទទួលខុសត្រូវលើការគ្រប់គ្រងហិរញ្ញវត្ថុ និង ការងាររដ្ឋបាលផ្សេងៗ ។ គាត់ចាប់ផ្តើមបំរើការងារនៅ ខែ តុលា ឆ្នាំ ២០០៧ ហើយ គាត់មានបទពិសោធន៍ ៥ឆ្នាំ ផ្នែកគណនេយ្យ ។

អ៊ីមែល: sokha@nepcambodia.org

លោក **ផាន់ ចាន់ហឿន** បំរើការងារនៅ NEP រយៈពេល១ឆ្នាំ កន្លះ ដោយបំរើការងារជាបុគ្គលិកស្ម័គ្រចិត្ត ហើយឥលូវ បានក្លាយជាបុគ្គលិកពេញសិទ្ធិ ដោយមានតួនាទីជាជំនួយការរដ្ឋបាល និង ហិរញ្ញវត្ថុ ។ ហឿនក៏ទទួលខុសត្រូវលើការកែ និង បញ្ចូលព័ត៌មានទៅក្នុងគេហទំព័រថ្មីរបស់ NEP ផងដែរ ។

អ៊ីមែល: chanhoeurn@nepcambodia.org

តាមរយៈអង្គការ VSO យើងមានទីប្រឹក្សាស្ម័គ្រចិត្ត ៣ រូបដែលកំពុងបំរើការងារនៅ NEP :

យើងមានលោកស្រី **Judy Baldwin** ជាទីប្រឹក្សាគ្រប់គ្រង គាត់មកពីប្រទេសកាណាដា ។ គាត់ចាប់ផ្តើមបំរើការងារនៅ ខែធ្នូ ឆ្នាំ ២០០៧ ហើយនឹងបន្តបំរើការងាររយៈពេល ២ឆ្នាំ ។ Judy ធ្វើការងារជាមួយខ្ញុំទៅលើកំណែទំរង់គោលនយោបាយ ការគ្រប់គ្រង និង ការអភិវឌ្ឍន៍ស្ថាប័ន និង ជួយគាំទ្របុគ្គលិកទៅលើផ្នែក ទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ ការសិក្សាស្រាវជ្រាវ និង ការគ្រប់គ្រងគំរោង ។

អ៊ីមែល: judy@nepcambodia.org

អ្នកស្រី **Janneke Harmsma** ជាទីប្រឹក្សារបស់យុទ្ធនាការជាសកលសំរាប់ការអប់រំ គាត់មានបទពិសោធន៍ច្រើនក្នុងវិស័យអប់រំ ហើយធ្លាប់បំរើការងារជា សភាទីក្រុងនៅក្នុងប្រទេសហូឡង់ ។ Janneke ធ្វើការងារជាមួយ ធារី ព្រមទាំងគណកម្មាធិការដឹកនាំGCE ក្នុងការអភិវឌ្ឍន៍យុទ្ធសាស្ត្រសំរាប់ GCE ក្នុងប្រទេសកម្ពុជា ដែលយុទ្ធសាស្ត្រនោះនឹងធ្វើឱ្យមានកំរិតនៃ ការចូលរួមពីសង្គមស៊ីវិលប្រកបដោយនិរន្តរភាព និង មានន័យពេញមួយឆ្នាំ ។ Janneke នឹងបំរើការងារជាមួយយើង រយៈពេល ៦ខែ ។

អ៊ីមែល: janneke@nepcambodia.org

អ្នកស្រី **Sarah Jago** ជាទីប្រឹក្សាតស៊ូមតិធ្លាប់មានបទពិសោធន៍ច្រើនផ្នែកអប់រំមនុស្សពេញវ័យ គាត់មកពីប្រទេសអង់គ្លេស ។ អ្នកស្រីនឹងបញ្ចប់ការងារស្រាវជ្រាវគុណតំលៃរបស់គ្រូបង្រៀនដែលគំរោងនោះចាប់ផ្តើមធ្វើនៅឆ្នាំ ២០០៦ ។ ការស្រាវជ្រាវនោះ ធ្វើការពិនិត្យអង្កេតលើអាកប្បកិរិយារបស់គ្រូបង្រៀន ក្នុងប្រទេសកម្ពុជាចំពោះបញ្ហា

ការងារ អនាគត និង ទឹកចិត្តរបស់ពួកគាត់ ។ Sarah នឹងបំរើការងាររយៈពេល ៦ ខែ ។

អ៊ីមែល: sarah@nepcambodia.org

## ព័ត៌មានថ្មីៗពីយុទ្ធនាការជាសកលសំរាប់ការអប់រំ(GCE)

“ *ការអប់រំប្រកបដោយគុណភាព ដើម្បីបញ្ចប់ការរើសអើង* “

ប្រធានបទ នៃសប្តាហ៍សកម្មភាពជាសកលសំរាប់ការអប់រំ ឆ្នាំ ២០០៨ ធ្វើបន្តពីប្រធានបទមុនៗ ដូចជា សិទ្ធិទទួលបានការអប់រំ ការអំពាវនាវឱ្យបញ្ចប់រាល់ទំរង់នៃការរើសអើងពីការអប់រំប្រកបដោយគុណភាព ។ ដើម្បីធានាថាការអប់រំសំរាប់ទាំងអស់គ្នាពិតជាអាចសំរេចបានមែននោះ បញ្ហាប្រឈមនោះមិនគ្រាន់តែ ធានាឱ្យមានការចូលរៀនជាសកលទាំងអស់គ្នានោះទេ ប៉ុន្តែត្រូវធានាថាការអប់រំនោះប្រកបដោយគុណភាពស្មើៗគ្នា ។

នៅប្រទេសកម្ពុជា ក្នុងអំឡុងពេលសប្តាហ៍សកម្មភាពជាសកលសំរាប់ការអប់រំ ពីថ្ងៃទី ២១ ដល់ ២៧ ខែមេសានេះ គណកម្មាធិការដឹកនាំ GCE មានផែនការរៀបចំឱ្យមានព្រឹត្តិការណ៍ ដូចខាងក្រោម :

- ការចូលគាល់ព្រះមហាក្សត្រពីសំណាក់កុមារជួបការលំបាកចំនួន ៧០ នាក់
- ព្រិត្តិការណ៏ការត្រឡប់ចូលសាលារៀនវិញ ដែលនឹងធ្វើនៅក្នុងខេត្ត កំពង់ស្ពឺ កំពង់ចាម កំពង់ឆ្នាំង សៀមរាប ពោធិសាត់ ព្រះវិហារ បាត់ដំបង និង កំពត
- ល្បែងកំសាន្តផ្សេងៗសំរាប់ការអប់រំ ដែលគ្រោងនឹងធ្វើនៅពហុកីឡាដ្ឋានជាតិអូឡាំពិកទីក្រុងភ្នំពេញ
- វេទិកាពិភាក្សាតុមូល និង កម្មវិធីចាក់ផ្សាយតាមវិទ្យុ

ប័ណ្ណផ្សព្វផ្សាយ (Posters) នឹងធ្វើការចែកចាយទៅឱ្យអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ ការិយាល័យអប់រំខេត្ត មន្ទីរអប់រំស្រុក សាលារៀន និង សហគមន៍នៅក្នុងខេត្តចំនួន ២០ ។ សំរាប់ព័ត៌មានលំអិតសូមចូលទៅគេហទំព័រ NEP www.nepcambodia.org

## គោលដៅការអប់រំសំរាប់ទាំងអស់គ្នា

យុទ្ធនាការជាសកលសម្រាប់ការអប់រំខិតខំធ្វើឱ្យសំរេចបាននូវគោលដៅទាំងនេះនៅឆ្នាំ ២០១៥ :

១- ពង្រីកការអប់រំ និង ថែទាំកុមារតូច ជាពិសេសកុមារងាយរងគ្រោះ និង កុមារក្រីក្រ

២- ផ្តល់ការអប់រំដោយឥតគិតថ្លៃ នៅកម្រិតអប់រំមូលដ្ឋានសម្រាប់ទាំងអស់គ្នា

៣- លើកកំពស់ការសិក្សា និង មុខជំនាញសម្រាប់យុវវ័យ និងមនុស្សពេញវ័យ

៤- បង្កើនអក្ខរកម្មមនុស្សពេញវ័យ ឱ្យបាន ៥០ ភាគរយថែមទៀត

៥- លុបបំបាត់គំលាតយេនឌ័រនៅឆ្នាំ ២០០៥ និង សមភាពយេនឌ័រនៅឆ្នាំ ២០១៥

៦- លើកកំពស់គុណភាពអប់រំ

## គេហទំព័រថ្មីរបស់ NEP

គេហទំព័រថ្មីរបស់ NEP ត្រូវបានរៀបចំឡើងដើម្បីឱ្យងាយស្រួលប្រើប្រាស់ និង ឱ្យសមាជិកអាចចូលទៅមើលព័ត៌មានបន្ថែមទៀត ។ សមាជិកក៏អាចចែករំលែកព័ត៌មានរបស់ខ្លួនដាក់លើគេហទំព័រយើងផងដែរ ។

NEP រីករាយនឹងផ្សព្វផ្សាយព័ត៌មាន របាយការណ៏ និង ព្រឹត្តិបត្រផ្សេងៗរបស់សមាជិកនៅលើគេហទំព័ររបស់យើង ។ ប្រសិនបើអ្នកមានមតិយោបល់អំពីមាតិកាព័ត៌មានផ្សេងៗនៅលើគេហទំព័រថ្មីរបស់យើង សូមផ្ញើរមកកាន់អ៊ីមែល : chanhoeurn@nepcambodia.org




*គេហទំព័រថ្មីរបស់* NEP : www.nepcambodia.org

## ព័ត៌មាន និង ព្រឹត្តិការណ៍នៅពេលខាងមុខ

*ព័ត៌មានបន្ថែមទៀតនឹងផ្តល់ជូននៅពេលខាងមុខឆាប់ៗ*

- កិច្ចប្រជុំសមាជិក NEP នៅថ្ងៃច័ន្ទ ទី ០២ ខែមិថុនា ឆ្នាំ ២០០៨ *របៀបវារៈនឹងផ្ញើរជូនពេលក្រោយ*
- ការវាយតំលៃពាក់កណ្តាលអាណត្តិរបស់ NEP និង ការអង្កេតសមាជិក
- ផ្តល់ព័ត៌មានបន្ថែមស្តីអំពី ការវាយតំលៃពាក់កណ្តាលអាណត្តិទៅលើ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និង កម្មវិធី គាំទ្រវិស័យអប់រំ និង ថវិកាពន្លឿនវិស័យអប់រំ (FTI)
- សិក្ខាសាលាស្តីអំពីច្បាប់អប់រំ

## ផ្តល់ព័ត៌មានមក NEP

NEP ចង់ស្តាប់មតិយោបល់ពីសមាជិករបស់ខ្លួននូវចំនុចដូចខាងក្រោម :

- សកម្មភាពពេលបច្ចុប្បន្ន និង បញ្ហាប្រឈម
- ការយល់ឃើញរបស់ខ្លួនអំពីដំណើរការអភិវឌ្ឍស្តីអំពិ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និង កម្មវិធីគាំទ្រវិស័យ អប់រំ និង ការផ្តល់ជាអនុសាសន៍

យើងក៏លើកទឹកចិត្តឱ្យសមាជិក NEP ជួយចែករំលែកព័ត៌មាន ដូចខាងក្រោម :

- តើ NEP អាចធ្វើអ្វីបានខ្លះទៅលើផ្នែកកសាងសមត្ថភាព ( សិក្ខាសាលា - វគ្គបណ្តុះបណ្តាល ) ប្រធានបទជាក់លាក់នៃការស្រាវជ្រាវ និង តំរូវការព័ត៌មានផ្សេងៗ
- តើអង្គការរបស់អ្នកអាចធ្វើអ្វីខ្លះ ដើម្បីជួយ NEP កសាងមូលដ្ឋានចំណេះដឹង និង បណ្តាញរបស់ សមាជិកភាពរបស់ខ្លួន និង ជួយលើកកំពស់ការយល់ដឹងរបស់ NEP ទៅលើបញ្ហាសំខាន់ៗ ។

ប្រសិនបើអ្នកមានព័ត៌មានថ្មីៗ ឬក៏គំនិតថ្មីៗដែលអ្នកចង់ដាក់ក្នុងព្រឹត្តិបត្ររបស់យើងសំរាប់ខែ កក្កដា សូមផ្ញើរមកកាន់ កញ្ញា លេង ធាវីតាមរយៈ អ៊ីមែល: theavy@nepcambodia.org.

**ទំនាក់ទំនង NEP :**

ផ្ទះលេខ ១១A, ផ្លូវ ២៤៨ សង្កាត់ វាលវង់ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ

ទូរស័ព្ទ : (៨៥៥) ២៣ ២២៤ ៧៧៤

អ៊ីមែល : info@nepcambodia.org

គេហទំព័រ: www.nepcambodia.org